## ច្បាប់ទូទៅសម្រាប់បន្ទប់ដាក់វិន័យ របស់ វិទ្យាល័យ ហ្វើនេស្ស (Furness)៖

| **ឧប្បត្តិហេតុ** | **ផលវិបាក** |
|---|---|
| មករៀនយឺតពេល | ដាក់ទណ្ឌកម្ម ៣០នាទី |
| មករៀនយឺតពេល ក្រោយម៉ោង ៩:០០ ព្រឹក | ដាក់ទណ្ឌកម្ម ៦០នាទី |
| ចេញពីសាលាដោយគ្មានការអនុញ្ញាត | ដាក់ទណ្ឌកម្មនៅសាលា ២ថ្ងៃ |
| ប្រើទូស័ព្ទដៃ | គេនឹងដកហូតទូរស័ព្ទដៃ មាតាបិតា/អាណាព្យាបាល ត្រូវមកយកទូរស័ព្ទវិញ នៅថ្ងៃពុធ នៅចន្លោះម៉ោង ២:០០ និង៣:០០ រសៀល។ |
| បទល្មើសលើច្បាប់ឯកសណ្ឋាន (ពាក់តែអាវឯកសណ្ឋាន ឬមិនស្លៀកពាក់ឯកសណ្ឋាន) | ដាក់ទណ្ឌកម្មកន្លះម៉ោងក្រោយម៉ោងសិក្សា ឬ ទណ្ឌកម្មនៅសាលា មិនឲ្យទៅថ្នាក់ |
| ប្រើ អាយផត (ipod) (ស្តាប់ចម្រៀង/ភ្លេង នៅក្រៅបន្ទប់ញ៉ាំបាយ) | |
| មិនទៅបង្ហាញខ្លួននៅបន្ទប់លេខ ០០១ នៅពេលមានសញ្ញាថាមានបញ្ហា នៅពេលព្រឹក | ទណ្ឌកម្មនៅសាលា មិនឲ្យទៅថ្នាក់ ១ថ្ងៃ |
| រំខាននៅក្នុងថ្នាក់រៀន (ជជែកគ្នា មិនធ្វើតាមការណែនាំ ។ល។) | ដាក់ទណ្ឌកម្មក្រោយម៉ោងសិក្សា ៣០នាទី |
| ដើរតាមរបៀងដោយគ្មានលិខិតអនុញ្ញាត | ដាក់ទណ្ឌកម្មក្រោយម៉ោងសិក្សា ៣០នាទី |
| វាយតប់គ្នា | បញ្ឈប់មិនឲ្យមករៀនបណ្តោះអាសន្ន ៣ថ្ងៃ |

### ច្បាប់ផ្សេងៗទៀត៖

**១. លិខិតអវត្តមានត្រូវឲ្យទៅ អ្នកស្រី Rainey នៅបន្ទប់លេខ ១១២។**
**២. លិខិតសម្រាប់ការមករៀនយឺតពេលពី វេជ្ជបណ្ឌិត មហាវិទ្យាល័យ ភ្នាក់ងារមើលអ្នកប្រព្រឹត្តបទល្មើសដែលនៅក្រោមការត្រួតពិនិត្យ តុលាការ បុណ្យសព ដែលសរសេរលើលិខិតជាផ្លូវការនៃកន្លែង នីមួយៗតែប៉ុណ្ណោះ ត្រូវឲ្យទៅបន្ទប់លេខ ០០១។ (គេមិនទទួលលិខិតដែលសរសេរដោយដៃទេ។)**
**៣. ពេលសិស្សកូតអត្តសញ្ញាណប័នចូលរៀន នៅពេលមានសញ្ញាថាមានបញ្ហាពួកគេត្រូវទៅបង្ហាញខ្លួននៅបន្ទប់លេខ ០០១ ជាបន្ទាន់។**
**៤. បើសិនជាសិស្សឈឺ ពួកគេត្រូវតែជួបជាមួយគិលានុបដ្ឋាក។ សិស្សានុសិស្សអាចចេញបើសិនជាមាតាបិតា ឬអាណាព្យាបាល មកយកពួកគេ។ ពួកគេមិនអាចចេញដោយខ្លួនឯងបានទេ។**
**៥. ការឆាប់ចេញពីសាលាត្រូវបំពេញដោយ អ្នកស្រី Rainey នៅបន្ទប់លេខ១១២ សម្រាប់ឧប្បត្តិហេតុភាគច្រើន។ ការឆាប់ចេញពីសាលាសម្រាប់បញ្ហាដាក់វិន័យ ត្រូវបំពេញនៅបន្ទប់ ០០១។**